**សេចក្តីប្រកាសព័ត៌មានរួមរវាងក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា**
**និង អង្គការសុខភាពពិភពលោក**

ភ្នំពេញ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៩

## ការរាតត្បាតជាសកលនៃជំងឺផ្តាសាយថ្មី H1N1 ឆ្នាំ ២០០៩

## ករណីស្លាប់ដំបូងពីការរាតត្បាតជាសកលនៃជំងឺផ្តាសាយថ្មី H1N1 ក្នុងប្រទេសកម្ពុជា

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមជំរាបជូនដំណឹងដ៏គួរអោយសោកស្តាយដល់សាធារណជនពីករណីស្លាប់ លើកដំបូងពីការរាតត្បាតជាសកលនៃជំងឺផ្តាសាយថ្មី H1N1 ក្នុងប្រទេសកម្ពុជា។

អ្នកជំងឺមានអាយុ ៤១ ឆ្នាំ ភេទ ស្រី មកពីទីក្រុងភ្នំពេញបានចាប់ផ្តើមចេញរោគសញ្ញានៃជំងឺផ្តាសាយពីថ្ងៃទី ១៨ ខែ កញ្ញា ហើយបានស្វែងរកការព្យាបាលនៅថ្ងៃទី ២០ ខែ កញ្ញា និងត្រូវបានដាក់អោយចូលសំរាកពេទ្យនៅថ្ងៃទី ២២ កញ្ញា។ គាត់ត្រូវបានធ្វើរោគវិនិច្ឆ័យឃើញថាមានផ្ទុកវិរុសជំងឺរាតត្បាតប្រភេទថ្មី H1N1 នៅថ្ងៃទី ២៤ កញ្ញា និង បន្ទាប់មកត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យកាល់ម៉ែត ដោយស្ថានភាពជំងឺរបស់គាត់កាន់តែធ្ងន់។ គាត់បានស្លាប់ដោយ បេះដូង និង សួតឈប់ដំណើរការនៅថ្ងៃទី ២៧ ខែ កញ្ញា។ ការអង្កេតកំពុងដំណើរការ ដើម្បីកំណត់នូវកត្តាប្រឈមមុខជាក់លាក់ទាំងឡាយដែលនាំអោយគាត់មានជំងឺធ្ងន់ធ្ងរ។

មកដល់ថ្ងៃទី ២៥ ខែកញ្ញា ជាសកលមានករណីស្លាប់ចំនួន ៣៩១៧ នាក់ដែលបណ្តាលមកពីជំងឺផ្តាសាយថ្មី H1N1 ហើយជំងឺនេះកើតមាននៅក្នុងប្រទេសចំនួន ១៩១ ។ នៅក្នុងប្រទេសកម្ពុជា គិតត្រឹមថ្ងៃទី ២៤ កញ្ញា មាន ៨៩ ករណីដែលបានបញ្ជាក់ថាមានជំងឺផ្តាសាយប្រភេទថ្មី ដោយមានការចំលងនៅក្នុងសហគមន៍ កើតឡើងនៅក្នុង ទីក្រុងភ្នំពេញ ខេត្តកណ្តាល តាកែវ កំពង់ស្ពឺ សៀមរាប និង បាត់ដំបង។

ចំនួនករណីនៅក្នុងប្រទេសកម្ពុជាត្រូវបានរំពឹងគិតថា នឹងកើនឡើងក្នុងពេលអនាគត រហូតដល់លក្ខណៈមួយដែលការធ្វើ ពិសោធន៍ ឬការរាយការណ៍ករណីបុគ្គលម្នាក់ៗ នឹងពុំមានប្រយោជន៍ទៀតទេ។ ក្រសួងសុខាភិបាល នឹងបន្តជូន ដំណឹងដល់សាធារណជនអំពីការវិវត្តន៍របស់ជំងឺនេះ តាមរយៈគេហទំព័ររបស់នាយកដ្ឋាន ប្រយុទ្ធនឹងជំងឺឆ្លង www.cdcmoh.gov.kh ។

ក្រសួងសុខាភិបាល ស្នើរអោយសមាជិកនៃសាធារណជនសំរាកនៅផ្ទះ ប្រសិនបើមានរោគសញ្ញាស្រដៀងជំងឺផ្តាសាយ( ក្តៅខ្លួន ក្អក ឈឺខ្លួន) និង ទាក់ទងមកលេខទូរស័ព្ទទាន់ហេតុការណ៍ របស់ក្រសួងសុខាភិបាល សំរាប់ដំបូន្មាន និង ការណែនាំជាបន្ថែមទៀត។ នៅក្នុងការប្រឹងប្រែងដើម្បីកាត់បន្ថយការរីករាលដាលជាទ្រង់ទ្រាយធំនៃជំងឺ នៅក្នុងប្រទេសកម្ពុជា អ្នកដែលត្រូវបានបញ្ជាក់ដោយមន្ទីរពិសោធន៍ ថាមានជំងឺផ្តាសាយថ្មី H1N1 នឹងត្រូវស្នើអោយទទួលការព្យាបាល និង ការដាក់អោយនៅដោយ ឡែកនៅផ្ទះ ឬ នៅមន្ទីរពេទ្យ សំរាប់រយៈពេល ៧ ថ្ងៃដោយគិតចាប់តាំងពីថ្ងៃចេញរោគសញ្ញា។

ក្រសួងសុខាភិបាលកំពុងធ្វើការ ដោយសហការជាមួយក្រសួងនានា ភ្នាក់ងារ និង ដៃគូអភិវឌ្ឍន៍ដទៃទៀតដើម្បីធានាការសំរបសំរួលសកម្មភាពអោយមានប្រសិទ្ធភាព សំរាប់សុខភាពសាធារណៈ និង សុវត្ថិភាព។ វិធានការនានារួមមានការបន្តការតាមដានរកអ្នកជំងឺ នៅតាមអាកាសយានដ្ឋានអន្តរជាតិទាំងអស់ និង ច្រកទ្វារព្រំដែន បង្កើនសមត្ថភាព មន្ទីរពេទ្យបន្តយុទ្ធនាការអប់រំជាសាធារណៈ និង ការរៀបចំសំរាប់ការបើកបវេសនកាល។

**ការណែនាំសំរាប់សាធារណៈជន**

**ការពារខ្លួនអ្នក និង គ្រួសារអ្នក:**

មធ្យោបាយដ៏មានប្រសិទ្ធភាព សំរាប់ការពារការរីករាលដាលនៃវីរុសជំងឺផ្តាសាយថ្មី H1N1 គឺត្រូវអនុវត្ត អោយបានល្អ និង ជាប្រចាំ នូវអនាម័យខ្លួនប្រាណជាមូលដ្ឋាន និង បង្រៀនកុមារអនុវត្តអនាម័យល្អ:

- ខ្ទប់មាត់ និង ច្រមុះ ជាមួយក្រដាស នៅពេលក្អក ឬ កណ្តាស និង បោះចោលនៅក្នុងធុងសំរាម
- លាងដៃអោយបានញឹកញាប់ ជាមួយសាប៊ូ និង ទឹក
- ហាមខាកស្តោះនៅទីសាធារណៈ
- ជៀសវាងប៉ះពាល់ផ្ទាល់ជាមួយអ្នកឈឺ។

**របៀបសំគាល់ជំងឺផ្តាសាយ និង វិធីត្រូវអនុវត្ត:**

**រោគសញ្ញានៃជំងឺផ្តាសាយថ្មី H1N1** ស្រដៀងនិងជំងឺផ្តាសាយតាមរដូវ និង រួមមាន: ក្តៅខ្លាំងលើសពី ៣៨ អង្សាសេ ក្អក ឈឺក្បាល ឈឺសាច់ដុំ ឈឺបំពង់ក ហៀរសំបោរ និង អស់កំលាំង។ ការចំលងរោគអាចចាប់ផ្តើមពី ១ ថ្ងៃ មុនចេញរោគសញ្ញា រហូត ៧ ថ្ងៃ ក្រោយចេញរោគសញ្ញា។

រាល់អ្នកមានរោគសញ្ញាទាំងនេះ គួរសំរាកនៅផ្ទះ ជៀសវាងទៅកន្លែងដែលមានមនុស្សកកកុញ និង ទាក់ទងទូរស័ព្ទទាន់ហេតុការណ៍សំរាប់ដំបូន្មាន និង ការណែនាំជាបន្ថែមទៀត។ មានតែអ្នកជំងឺធ្ងន់ធ្ងរប៉ុណ្ណោះដែលត្រូវការសំរាកពេទ្យ។

ការថប់ និង ពិបាកដកដង្ហើម អាចកើតមានក្នុងករណីតិចតួច។ បើសិនបញ្ហាទាំងនេះកើតមាននៅក្នុង ក្រុមដែលប្រឈមមុខត្រូវស្វែងរកការព្យាបាល។ ក្រុមប្រឈមមុខរួមមាន អ្នកដែលមានជំងឺរ៉ាំរ៉ៃ ដូចជា: ជំងឺបេះដូង សួត ឬ តំរងនោម ជំងឺទឹកនោមផ្អែម និង អ្នកដែលមានប្រព័ន្ធការពារខ្សោយដូចជា ជំងឺមហារីក ឬ អ្នកដែលផ្ទុកមេរោគ អេដស៍។

**ការព្យាបាលគឺស្រដៀងទៅនឹង ជំងឺផ្តាសាយតាមរដូវ** ហើយរួមមាន: ផឹកទឹកអោយបានច្រើន សំរាកនិង ប្រើថ្នាំ ប៉ារ៉ាសេតាម៉ុល (Paracetamol) ដើម្បីបន្ថយកំដៅ និង ការឈឺសាច់ដុំ។

ករណីភាគច្រើន មិនចាំបាច់ប្រើឱសថប្រឆាំងវិរុសទេ។ សព្វថ្ងៃនេះ ពុំទាន់មានវ៉ាក់សាំងសំរាប់ជំងឺផ្តាសាយថ្មី H1N1 នៅឡើយទេ ហើយវ៉ាក់សាំងនេះនឹងមិនមានប្រើប្រាស់ជាទូលាយ នៅក្នុងរយៈពេលខ្លីខាងមុខនេះទេ។

សំរាប់ព័ត៌មានបន្ថែមទៀតអំពីជំងឺផ្តាសាយថ្មី H1N1 សូមទាក់ទងមកលេខទូរស័ព្ទទាន់ហេតុការណ៍:

**១១៥ ( មិនគិតថ្លៃ)**

**០១២ ៤៨៨ ៩៨១**

**០៨៩ ៦៦៩ ៥៦៧**

សំរាប់ព័ត៌មានបន្ថែមទៀត សូមធ្វើការទាក់ទង:

**ក្រសួងសុខាភិបាល**

វេជ្ជបណ្ឌិត **សុខ ទូច**

ទូរស័ព្ទ: +៨៥៥ ០១២ ៨៥៦ ៨៤៨

វេជ្ជបណ្ឌិត **លី សុវ៉ាន់**

ទូរស័ព្ទ: + ៨៥៥ ០១២ ៨២៥ ៤២៤

**អង្គការសុខភាពពិភពលោក**

វេជ្ជបណ្ឌិត **Michael O'Leary:**

ទូរស័ព្ទ: +៨៥៥ ០២៣ ២១៦ ៦១០

វេជ្ជបណ្ឌិត **Nima Asgari:**

ទូរស័ព្ទ: +៨៥៥ ០២៣ ២១៦ ៦១០